# របាយការណ៍ប្រចាំខែឧសភា ឆ្នាំ ២០១៦ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ

នៅក្នុងខែឧសភា ឆ្នាំ២០១៦ មន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ បានបំពេញភារកិច្ចសម្រេចលទ្ធផលដូចខាងក្រោម÷

1. <u>ស្ថានភាពមន្ត្រីរាជការ</u>÷

ស្ថានភាពមន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ មានមន្ត្រីក្របខណ្ឌ និងកិច្ចសន្យាសរុបចំនួន ៣១ នាក់ ស្ត្រី ០៤ នាក់ ដឹកនាំដោយប្រធានមន្ទីរ ០១រូប និងអនុប្រធានមន្ទីរ ០២រូប ។

2. <u>សកម្មភាពថ្នាក់ដឹកនាំមន្ទីរ</u>÷

- ចូលរួមវេទិកាសាធារណៈចំនួន ០៤ដង
- ចូលរួមប្រជុំការងារលទ្ធកម្មវាយតម្លៃប្រគល់ទទួល បញ្ចប់សុពលភាពជួសជុលផ្លូវជនបទ ក្រាលក្រួសក្រហម ០១ ខ្សែ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ សាលប្រជុំសាលាខេត្ត
- ចូលរួមប្រជុំក្រុមប្រឹក្សាខេត្ត លើកទី២៣ ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ សាលប្រជុំក្រុមប្រឹក្សាខេត្តក្រចេះ
- ចូលរួមប្រជុំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៧-២០១៩ ថ្ងៃទី ២៨ ខែមេសា ២០១៦
- ចូលរួមពិធីសំណេះសំណាល និងផ្តល់អណ្តូងទឹកតាមសាលារៀន ថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០១៦
- ចូលរួមពិធីសំណេះសំណាល និងផ្តល់អណ្តូងទឹកតាមសាលារៀន ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ឃុំកន្ទួត និងឃុំស្វាយជ្រះ
- ចូលរួមសិក្ខាសាលា ស្តីពីយេនឌ័រ និងកាចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៦ សាលប្រជុំសណ្ឋាគារលីជី
- ចូលរួមពិធីផ្សព្វផ្សាយភារកិច្ចតួនាទីរបស់ក្រុមប្រឹក្សាសកម្មភាពជនពិការ និងផែនកាយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០១៤-២០១៨ ថ្ងៃទី០៤ ខែឧសភា ឆ្នាំ ២០១៦ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមប្រជុំផ្សព្វផ្សាយអនុក្រឹត្យលេខ៥៦ ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៦ សាលប្រជុំសាលាខេត្ត
- ចូលរួមប្រជុំពិនិត្យ ពិភាក្សាករណីសំណើសុំដីសម្បទានសង្គមកិច្ចរបស់ពលរដ្ឋ ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៦ សាលប្រជុំសាលាខេត្ត
- ចូលរួមប្រជុំស្តីពី ការប៉ាន់ប្រមាណរហ័សអំពីស្ថានភាពគ្រោះរាំងស្ងួត ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៦ សាលប្រជុំសាលាខេត្ត
- ចូលរួមប្រជុំត្រៀមរៀបចំពិធីមិទ្ទិញអបអរសាទរខួបលើកទី១៥៣ ទិវាអឡចន្ទក្រហម ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៦ សាលប្រជុំសាលាខេត្ត
- ចូលរួមប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមេសា ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ សាលប្រជុំសាលាខេត្ត

- ចូលរួមប្រជុំត្រួតពិនិត្យតារាងប្រៀបធៀបកើនឆ្នាំ ២០១៥ ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦ សាលប្រជុំមន្ទីរសេដ្ឋកិច្ច
- ចូលរួមប្រជុំវិសាមញ្ញលើកទី១៤ របស់ក្រុមប្រឹក្សាខេត្ត ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៦ សាលប្រជុំក្រុមប្រឹក្សាខេត្ត
- ចូលរួមពិធីសូត្រមន្តចម្រើនព្រះជន្មព្រះករុណាព្រះបាទបរមនាថ នរោត្តមសីហមុនី ថ្ងៃទី១១ ខែឧសភា ឆ្នាំ ២០១៦ នៅសាលមហោស្រពខេត្ត
- ចូលរួមពិធីសំណេះសំណាល ជាមួយអតីតយុទ្ធជន ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ នៅសាលមហោស្រពខេត្ត
- ចូលរួមប្រជុំពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ សាលប្រជុំក្រុមប្រឹក្សាខេត្ត
- ចូលរួមធ្វើបទបង្ហាញស្តីពីគម្រោងទឹកស្អាត និងអនាម័យសុខភាពសហគមន៍ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ នៅសាលប្រជុំសណ្ឋាគារលីជី
- ចូលរួមប្រជុំសាមញ្ញក្រុមប្រឹក្សាខេត្តទី២៤ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ សាលប្រជុំក្រុមប្រឹក្សាខេត្ត ។

3. ***សកម្មភាពតាមការិយាល័យ***÷

### 3.1. ការិយាល័យរដ្ឋបាល និងកិច្ចការទូទៅ

ក. ផ្នែកការងារលិខិតចូល ÷ សរុបចំនួន ៩៦ លេខ ក្នុងនោះមាន :

- លិខិតចូលពីអង្គភាពនានាក្រៅមន្ទីរ ចំនួន ៧៧ លេខ
- លិខិតក្រសួងសាមី និងអង្គភាពក្រោមឱវាទមន្ទីរ ចំនួន ១៩ លេខ

ខ. ផ្នែកការងារលិខិតចេញ ÷

- លិខិតចេញទៅបណ្តាអង្គភាពនានាក្រៅមន្ទីរ ចំនួន ៣៣ លេខ
- លិខិតចេញពាក់ព័ន្ធស្ថានភាពមន្ត្រីរាជការ ចំនួន ៤១ លេខ
- លិខិតចេញទូទៅ លិខិតអញ្ជើញ និងសេចក្តីជូនដំណឹង ចំនួន ០៤ លេខ
- លិខិតចេញទៅបណ្តាអង្គភាពនានា និងក្រសួងសាមី ចំនួន ១៥ លេខ

គ. ផ្នែកបញ្ជីវត្តមាន÷ ពិនិត្យការចុះបញ្ជីវត្តមានប្រចាំថ្ងៃ ។

### 3.2. ***ការិយាល័យផ្លូវជនបទ***÷

***សកម្មភាពការងារ***

- ចុះធ្វើបច្ចុប្បន្នភាពផ្លូវ ប្រភេទទី៣ និងប្រភេទទី៤ បានចំនួន ៣ខ្សែ ប្រវែង ២២ ០០០ ម៉ែត្រ ស្ថិតនៅ ឃុំសំបុក ឃុំចង្រ្កង់ ឃុំថ្មគ្រែ ឃុំគោលាប់ ឃុំកន្ទួត និងឃុំថ្មី ស្រុកចិត្របុរី ខេត្តក្រចេះ
- បញ្ជាក់បច្ចេកទេសគម្រោងមូលនិធិឃុំសង្កាត់ស្រុក ឆ្នាំ២០១៦ បានចំនួន ០១ គម្រោង របស់ទីចាត់ការផែនការ និងវិនិយោគរដ្ឋបាលខេត្តក្រចេះ

- ចុះសិក្សាពិនិត្យ និងវាយតម្លៃស្ពានឈើទ្រុឌទ្រោម ០២កន្លែង ស្ថិតនៅភូមិអន្ទង់វៀន ឃុំកន្ទួត ស្រុកចិត្របុរី
- ចុះពិនិត្យ ការងារជួសជុលស្ពានឈើទ្រុឌទ្រោម ០២កន្លែង ស្ថិតនៅភូមិអន្ទង់វៀន ឃុំកន្ទួត ស្រុកចិត្របុរីបានចំនួន ៥ លើក
- តំណាងក្រុមការងារក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ តំណាងក្រសួងអភិវឌ្ឍន៍ជនបទ ក្រុមការងារនាយកដ្ឋានផ្លូវលំជនបទ និងក្រុមការងារមន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ ចុះពិនិត្យសិក្សា និងវាយតម្លៃ ជួសជុលបន្ទាន់ ផ្លូវភូមិស្ទឹងទ្រ ប្រវែវង ៤ ៥០០ ម៉ែត្រ ស្ថិតនៅឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ
- ចុះពិនិត្យការងារជួសជុលបន្ទាន់ផ្លូវភូមិស្ទឹងទ្រ ប្រវែវង ៤ ៥០០ ម៉ែត្រ ស្ថិតនៅឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ បានចំនួន ១លើក
- ចុះពិនិត្យការងារជួសជុលផ្លូវថែទាំជាលក្ខណៈខួបរបស់គម្រោង RIP-III ចំនួន ០៣ខ្សែ ប្រវែង ២០ ៨០០ ម៉ែត្រ ស្ថិតនៅឃុំព្រែកប្រសព្វ ឃុំកំពង់គរ និងឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ ចំនួន ០១លើក
- ចុះពិនិត្យការងារជួសជុលថែទាំជាលក្ខណៈខួប ចំនួន ១ ខ្សែ ប្រវែង ១០ ០០០ ម៉ែត្រ ស្ថិតនៅភូមិព្រែកចំឡាក់ (ឧបសម្ពន្ធ័ភូមិខ្សាច់វែង) ទៅភូមិដារជ្រៃ ឃុំកញ្ជរ ស្រុកឆ្លូង បានចំនួន ០៣លើក ។

__លទ្ធផលការងារ__

- ការងារផ្លូវថែទាំជាលក្ខណៈខួបរបស់គម្រោង RIP-III ចំនួន ០៣ខ្សែ ប្រវែង២០ ៨០០ម៉ែត្រ ស្ថិតនៅឃុំព្រែកប្រសព្វ ឃុំកំពង់គរ ឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ លទ្ធផលសម្រេចបាន ១០០%។
- ការងារជួសជុលថែទាំជាលក្ខណៈខួប ចំនួន ០១ខ្សែ ប្រវែង ១០ ០០០ម៉ែត្រ ស្ថិតនៅភូមិព្រែកចំឡាក់ (ឧបសម្ពន្ធ័ ភូមិខ្សាច់វែង) ទៅភូមិដារជ្រៃ ឃុំកញ្ជរ ស្រុកឆ្លូង លទ្ធផលសម្រេចបាន ១០%។
- ការងារជួសជុលបន្ទាន់ ផ្លូវភូមិស្ទឹងទ្រ ប្រវែង ៤ ៥០០ ម៉ែត្រ ស្ថិតនៅឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ លទ្ធផលសម្រេចបាន ១០%។
- ការងារជួសជុលស្ពានឈើទ្រុឌទ្រោម ០២កន្លែង ស្ថិតនៅភូមិអន្ទង់វៀន ឃុំកន្ទួត ស្រុកចិត្របុរី លទ្ធផលសម្រេចបាន ៧០%។

## 3.3. ការិយាល័យផ្គត់ផ្គង់ទឹកជនបទ÷

- ចុះពិនិត្យនិងវាយតម្លៃ អណ្តូងស្នប់ខូចចំនួន ០២ កន្លែង ស្ថិតនៅភូមិបឹងរុន ឃុំសំបុក តាមការស្នើសុំក្នុងអង្គប្រជុំសាមញ្ញ លើកទី២៣ អាណត្តិទី២ ឆ្នាំ២០១៦ របស់ក្រុមប្រឹក្សាខេត្ត ។
- ចុះជួសជុលអណ្តូងស្នប់ខូចបានចំនួន ២២អណ្តូង
    - ស្រុកចិត្របុរីចំនួន ១៣អណ្តូង

- ស្រុកស្ទួលចំនួន ០៣ អណ្តូង
- ស្រុកព្រែកប្រសព្វចំនួន ០៦ អណ្តូង ។

3.4. <u>**ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ**</u>÷ (គ្មានសកម្មភាព)

3.5. <u>**ការិយាល័យអភិវឌ្ឍន៍សហគមន៍**</u>÷

ចុះចុះត្រួតពិនិត្យតាមដានសកម្មភាព និងធ្វើបច្ចុប្បន្នភាពសមាសភាព គណៈកម្មាធិការ អភិវឌ្ឍន៍ភូមិ (គ.អ.ភ) ចំនួន ២០ ភូមិ ក្នុងឃុំ៣ គឺឃុំស្ទួល (០៧ភូមិ) ឃុំស្រែចារ (០៦ភូមិ) និងឃុំ២ធ្នូ (០៧ភូមិ) ។

3.6. <u>**ការិយាល័យជនជាតិដើមភាគតិច**</u>÷ (គ្មានសកម្មភាព)

3.7. <u>**ការិយាល័យថែទាំសុខភាពជនបទ**</u>÷

ចុះធ្វើ PVA (សិក្សាស្ថានភាពទិន្នន័យភូមិ )នៅស្រុកចិត្របុរី និងស្រុកឆ្លូង អ្នកចូលរួមមាន ចំនួន ១៣៧នាក់ ស្រ្តី៦៨នាក់ ក្នុងនោះ÷

- ស្រុកចិត្របុរី ឃុំបុសលាវ អ្នកចូលរួម ៤០ នាក់ ស្រ្តី ២៧ នាក់ ។
- ស្រុកឆ្លូង ឃុំព្រែកសាម៉ាន់អ្នកចូលរួម ៥០ នាក់ ស្រ្តី១៩នាក់ ឃុំខ្សាច់អណ្តែត អ្នកចូលរួម ៤៧ នាក់ ស្រ្តី ២២ នាក់។

3.8. <u>**ការងារបណ្តុះបណ្តាលមន្ត្រីរាជការ**</u>÷

4. <u>**ទិសដៅបន្ត**</u>÷

- ចុះជួសជុលថែទាំជាលក្ខណៈខួប ចំនួន ០១ខ្សែ ប្រវែង ១០ ០០០ ម៉ែត្រ ស្ថិតនៅភូមិព្រែកចំឡាក់ (ឧបសម្ពន្ធ័ ភូមិខ្សាច់វែង) ទៅភូមិដារជ្រៃ ឃុំកញ្ជរ ស្រុកឆ្លូង
- ចុះជួសជុលបន្ទាន់ផ្លូវភូមិស្ទឹងទ្រប្រវែង៤ ៥០០ម៉ែត្រ ស្ថិតនៅឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ
- ចុះជួសជុលស្ពានឈើទ្រុឌទ្រោម ២កន្លែង ស្ថិតនៅភូមិអន្ទង់វៀន ឃុំកន្ទួត ស្រុកចិត្របុរី
- ចុះជួសជុលផ្លូវថែទាំជាលក្ខណៈប្រចាំ ចំនួន ០៣ខ្សែ ប្រវែង ៥១ ០០០ ម៉ែត្រ ស្ថិតនៅឃុំកំពង់ដំរី ស្រុកឆ្លូង និងឃុំអូរគ្រៀង ស្រុកសំបូរ
- ចុះស្រង់ទិន្នន័យផ្លូវ និងធ្វើបច្ចុប្បន្នភាពផ្លូវ នៅស្រុកចិត្របុរី ស្រុកសំបូរ និងស្រុកស្នួល
- បន្តចុះជួសជុលអណ្តូងស្នប់ខូច នៅស្រុកឆ្លូងឃុំកំពង់ដំរី
- ចុះទៅតាមដានសកម្មភាព និងធ្វើបច្ចុប្បន្នភាពគ.អ.ភ ឃុំកន្ទួត ឃុំដារ និងឃុំថ្មី ក្នុងស្រុក ចិត្របុរី ។

**ប្រធានមន្ទីរ**